**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិសាសនាព្រះមហាក្សត្រ**

**កិច្ចព្រមព្រៀង**

**រវាងតំណាងសហជីពកម្មករកម្ពុជានិងតំណាងកម្មករប្រចាំរោងចក្រជាមួយក្រុមហ៊ុនស៊ីភីស៊ីជី**

ឆ្នាំ២០២០ ខែកក្កដា ថ្ងៃទី ១៧ វេលាម៉ោង១រសៀល នៅក្នុងការិយាល័យក្រុមហ៊ុនស៊ីភីស៊ីជី ដែលមានទីតាំងស្ថិតនៅភូមិឈូក ឃុំគោករវៀង ស្រុកជើងព្រៃ ខេត្ត កំពង់ចាម ។មានកិច្ចប្រជុំពិភាក្សាអំពីរដំណើរការសុំព្យួរការងារកម្មករនិយោជិតនៅថ្ងៃទី១១ ខែ សីហា ឆ្នាំ ២០២០ ដល់ ថ្ងៃទី២៩ ខែ កញ្ញា ឆ្នាំ២០២០។

# ខ្លឹមសារនៃកិច្ចព្រមព្រៀង

ដោយសារហេតុការកើតឡើងមានជំងឺ ( Covide 19 )រីករាលដាលពេញទូទាំងពិភពលោក ធ្វើអោយរោងចក្រជាច្រើន ជួបនិងហានិភ័យអត់មានការបញ្ជាទិញពីភ្ញៀវ។ដើម្បីរក្សាលំនឹងរោងចក្រនៅកម្ពុជាទើបរដ្ឋាភិបាលពិភាក្សាសំរេចអោយរោងចក្រមួយចំនួនដែលអត់មានការបញ្ជាទិញ,ធ្វើការព្យួរការងារមួយរយះ។ហេតុផលដូចនេះហើយ ទើបបងប្អូនកម្មករនិយោជិតរោងចក្ររបស់យើងត្រូវព្យួរការងារមួយរយះ។អាស្រ័យហេតុនេះក្រុមហ៊ុនមានចំណុចត្រូវអោយបងប្អូនសហការដូចខាងក្រោមះ

**ចំណុចទី១:** ក្រុមហ៊ុនបានរៀបចំអោយបងប្អូនសំរាក( ចំនួន៥០ថ្ងៃ )។

- ចាប់ផ្តើមអោយសំរាកពីថ្ងៃទី១១ ខែ សីហា ឆ្នាំ២០២០ ដល់ថ្ងៃទី ២៩ ខែកញ្ញា ឆ្នាំ ២០២០( ៥០ថ្ងៃ )
- បើកប្រាក់ឧបត្ថម្ភព្យួរការងារសំរាប់ក្រុមហ៊ុន៣០ដុល្លាក្នុង១ខែ, សំរាប់រដ្ឋាភិបាល៤០ដុល្លា ក្នុង១ខែ ។
- ថ្ងៃទី១០ខែសីហាក្រុមហ៊ុនបើកប្រាក់ឧបត្ថម្ភមុនថ្ងៃព្យួរ១ថ្ងៃ
- សំរាប់កម្មករព្យួរការងារវគ្គទី១ក្រុមហ៊ុនរៀបចំថ្ងៃទី ៣,៤,៥,៦,៧ ប៉ូវសំរាកបុណ្យចូលឆ្នាំខ្មែរ៥ថ្ងៃ។
- សំរាប់កម្មករព្យួរការងារវគ្គទី១ប្រាក់ខែខែ៨គឺបើកនៅថ្ងៃទី១០ខែកញ្ញាឆ្នាំ២០២០ខាងមុខ។

**ចំណុចទី២:** ក្នុងគំឡុងពេលព្យួរបើក្រុមហ៊ុនមានឥវាន់ធ្វើមុនការកំណត់រយៈពេលព្យួរ ពេលនោះប្រាក់សំរាប់រយៈពេលព្យួរដែលនៅសល់ក្រុមហ៊ុននឹងធ្វើការកាត់កងតាមចំនួនថ្ងៃដែលបានធ្វើការ។

**ចំណុចទី៣ :**ក្នុងកំឡុងពេលព្យួរបងប្អូនត្រូវទំលាក់លេខទូរស័ព្ទណាដែលត្រឹមត្រូវនិងគេចូលដើម្បីមានភាពងាយស្រួលក្នុងការតំនាក់ទំនងអោយបងប្អូនទៅបើកប្រាក់ក្នុងរយះពេលព្យួរពីរដ្ឋាភិបាល។

**ចំណុចទី៤ :** ទឹកប្រាក់ឧបត្ថម្ភព្យួរការងាររបស់រដ្ឋាភិបាលគឺមានចំនួន៤០ដូល្លា ប្រាក់ឧបត្ថម្ភព្យួរគឺបើកតាមរយះភ្នាកងាវីង។

បញ្ជាក់: បើបងប្អូនណាទំលាក់លេខមិនត្រឹមត្រូវគេមិនចូលនិងលេខអត្តសញ្ញាណប័ណ្ណមានបញ្ហា។ហើយបើកប្រាក់ក្នុងកំឡុងពេលព្យួរមិនបានពីរដ្ឋាភិបាល, នោះក្រុមហ៊ុនមិនទទួលខុសត្រូវឡើយ។

កិច្ចប្រជុំពិភាក្សានេះត្រូវបានចប់សព្វគ្រប់វេលាម៉ោង៣រសៀលនៅថ្ងៃខែឆ្នាំដដែលក្រោមបរិយាកាស រីករាយ និងយោគយល់គ្នា។

**សមាសភាពចូលរួមមាន:** (មានបញ្ជីអវត្តមានភ្ជាប់ជូន)

តំណាងរោងចក្រស៊ីភីស៊ីជី ខូរអិលធីឌី : លោក ឈឹនមីន ស្យុង ប្រធានគ្រប់គ្រងរោងចក្រ

តំណាងរោងចក្រស៊ីភីស៊ីជី ខូរអិលធីឌី : លោកស្រី សេង អ៊ុំ ឆេង អ្នកបកប្រែ

តំណាងសហជីបប្រចាំរោងចក្រស៊ីភីស៊ីជី ខូរអិលធីឌី: លោកស្រី ខូវ និមល ប្រធានសហជីប

តំណាងសហជីបប្រចាំរោងចក្រស៊ីភីស៊ីជី ខូរអិលធីឌី: លោកស្រី ម៉ា គឹម ស្រ៊ួន អនុ ប្រធានសហជីប

តំណាងកម្មករប្រចាំរោងចក្រស៊ីភីស៊ីជី ខូអិលធីឌី: លោកស្រី រីម ស្រី នាត តំណាងកម្មករ

តំណាងកម្មករប្រចាំរោងចក្រស៊ីភីស៊ីជី ខូអិលធីឌី: លោកស្រី យន់ ថារី តំណាងកម្មករ

និងមានតំណាងសហជីព,តំណាងកម្មករនិងប្រធានក្រុម ប្រធានផ្នែកផ្សេងទៀតចូលរួមដែលមានរាយឈ្មោះដូចខាងក្រោម៖

តំណាងសហជីបនិងតំណាងកម្មករប្រចាំរោងចក្រស៊ីភីស៊ីជី

ខូវ និមល :

ម៉ា គឹម ស្រ៊ួន :

រីម ស្រី នាត:

យន់ ថារី :

តំណាងក្រុមហ៊ុនស៊ីភីស៊ីជី

ឈឹនមីន ស្យុង

សេង អ៊ុំ ឆេង (អ្នកបកប្រែ)